# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ: ……………..ស.ខ.ក.ក.

# សារជូនពរ

## ឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ គ្រឹស្តសករាជ ២០១៥

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់!

សូមគោរពបងប្អូនជនរួមជាតិជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ

ក្នុងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា សហគមន៍ខ្មែរកម្ពុជាក្រោមនិងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមអបអរសាទរស្វាគមន៍ទេវតាឆ្នាំថ្មី ព្រះនាមរាក្សសទេវី ដែលមានភារកិច្ចចុះមកថែរក្សាមនុស្សលោកក្នុងដែនចក្រវាលយើងនេះយ៉ាងកក់ក្តៅជាទីបំផុត។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំ សូមលើកហត្ថបួងសួងទេវតាឆ្នាំថ្មី ព្រះនាមរាក្សសទេវី ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាទាំងមួយម៉ឺនលោកធាតុ សូមព្រះមេត្តាជួយនាំយកទៅជាមួយឆ្នាំចាស់នូវអពមង្គលឧបទ្រពចង្រៃទាំងឡាយទាំងពួងកុំឲ្យមានសេសសល់ នៅក្នុងសង្គមនិងខន្ធសណ្តាននៃប្រជារាស្ត្រខ្មែរឡើយ។ ជាមួយគ្នានេះដែរ សូមព្រះមេត្តាជួយប្រោះព្រំបន្ធំបារមីដល់ប្រជារាស្ត្រខ្មែរទាំងអស់ឲ្យមានភាពក្លាហានក្រោកឡើងការពារទឹកដី ការពារយុត្តិធម៌ ការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងទទួលបាននូវសេចក្តីសុខសេចក្តីចម្រើនសុភមង្គលគ្រប់ក្រុមគ្រួសារ និងសម្រេចបានជោគជ័យគ្រប់ការងារ។

*បពិត្រព្រះករុណាព្រះគុណម្ចាស់គ្រប់ព្រះអង្គជាទីសក្ការៈ !*

*បងប្អូនរួមជាតិជាទីស្នេហា !*

ពិតមែនតែឆ្នាំចាស់បានកន្លងផុតទៅ តែយើងក៏មិនអាចបំភ្លេចសមិទ្ធិផលដ៏សំខាន់ៗ ដែលផ្តើមចេញពីការតស៊ូ និងពលីកម្មរបស់ព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិពីមួយឆ្នាំទៅមួយឆ្នាំដែរ។ ជាក់ស្តែងឆ្នាំចាស់ទើបតែកន្លងទៅនេះ យើងបានសម្រេចការងារជាប្រវត្តិសាស្ត្រដ៏សំខាន់មួយនោះគឺរដ្ឋាភិបាលបារាំងបានអនុញ្ញាតឲ្យយើងទៅស្រាវជ្រាវយកឯកសារ ដែលពាក់ព័ន្ធនឹងការកាត់ផ្ទេរទឹកដីខ្មែរកម្ពុជាក្រោមឲ្យយួន។ ការស្រាវជ្រាវយើងបានរកឃើញឯកសារពាក់ព័ន្ធទាំងនោះ ជាង ៥.០០០ ទំព័រ។ បច្ចុប្បន្ន ក្រុមកាងាររបស់យើងកំពុងមមាញឹកក្នុងការថតចម្លងយកឯកសារទាំងនោះនៅ

បណ្ណសារដ្ឋានជាតិបារាំង Aix-En-Provence ប្រទេសបារាំង ដែលត្រូវចំណាយថវិកាចំនួន ១៦.០០០ អឺរ៉ូ។

សហគមន៍ខ្មែរកម្ពុជាក្រោម មានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា យើងនឹងទទួលបានជោគជ័យថ្មីៗថែមទៀតបន្ទាប់ពីយើងថតចម្លងឯកសារជាផ្លូវការរួច។

ដើម្បីទទួលបានជោគជ័យជូនមាតុភូមិយើងក្នុងឆ្នាំថ្មីថែមទៀត ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវ និងអង្វរករយ៉ាងទទូចដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមជាតិទាំងអស់ ព្រះមេត្តា និងមេត្តា ជម្រុះចោលឲ្យអស់នូវអស្មិមានៈមិច្ឆាទិដ្ឋិដោយចាប់យកអំពើល្អប្រកបដោយសម្មាទិដ្ឋិរួបរួមសាមគ្គីជាធ្លុងមួយ (ខ្មែរលើ ខ្មែរក្រោម ខ្មែរកណ្ដាល ជាខ្មែរតែមួយ) ជាមួយសហគមន៍ខ្មែរកម្ពុជាក្រោម ដើម្បីតស៊ូទាមទារសិទ្ធិសេរីភាពតាមគោលការណ៍អង្គការសហប្រជាជាតិជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោមឲ្យខាងតែបាន។

ជាថ្មីម្ដងទៀត ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិនេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរ និងជូនពរបវរមហាប្រសើរដល់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមជាតិទាំងអស់ទទួលបាននូវសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការ សូមបានរួចចាកផុតពីការជិះជាន់ធ្វើទុក្ខបុកម្នេញ ការរំលោភបំពាននៃសិទ្ធិសេរីភាព អំពើអយុត្តិធម៌ផ្សេងៗ និងបានប្រកបនូវពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរព្រះគុណ និងអរគុណ!

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៥

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

ទីប្រឹក្សាអនុប្រធានទី១ រដ្ឋសភា

អតីតសមាជិកព្រឹទ្ធសភា

---

ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦

E-mail: thachsetha13@gmail.com, Website: khmerkromngo.org